**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ១៤២ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ធានានូវប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងវិភាគ តាមដានសភាពការណ៍ក្នុងកិច្ចការអាស៊ាន និងអន្តរជាតិក្នុងវិស័យទេសចរណ៍

- សម្របសម្រួលរៀបចំ និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យាកំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយស្ថាប័នទេសចរណ៍អាស៊ាន និងអន្តរជាតិ
- លើកកម្ពស់ការងារឱ្យស្របតាមការវិវឌ្ឍឈានទៀងនៃវិស័យទេសចរណ៍ និងភាពចាំបាច់ ដើម្បីចូលរួមពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព។

## ជំពូកទី ២
## តួនាទី និងភារកិច្ច

**ប្រការ ៣.-**

**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន** ចំណុះអគ្គនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ និងជាសេនាធិការឱ្យក្រសួងទេសចរណ៍ ទទួលបន្ទុកការងាររៀបចំ និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានា ជាមួយស្ថាប័នទេសចរណ៍អន្តរជាតិ អង្គការ សមាគមទេសចរណ៍ជាតិ តំបន់ និងអន្តរជាតិ និងស្វែងរកសង្គហអភិវឌ្ឍន៍បច្ចេកទេសសំដៅធានាដល់ការដឹកនាំ គ្រប់គ្រងកិច្ចការគតិយុត្ត និងកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌអន្តរជាតិ និងអាស៊ាន។

**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងការអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និង អាស៊ាន
- សហការសិក្សាស្រាវជ្រាវរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការអាស៊ាន និងអន្តរជាតិ
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី អាស៊ាន និងអន្តរជាតិ
- គ្រប់គ្រង វិភាគ និងតាមដានសភាពការណ៍ក្នុងកិច្ចការអាស៊ាន និងអន្តរជាតិក្នុងវិស័យទេសចរណ៍
- សម្របសម្រួលការរៀបចំ និងជំរុញការអនុវត្តកិច្ចព្រមព្រៀងអនុស្សរណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យាកំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយស្ថាប័នទេសចរណ៍អាស៊ាន និងអន្តរជាតិ
- សហការរៀបចំកិច្ចប្រជុំ ព្រឹត្តិការណ៍ទេសចរណ៍ និងសន្និសីទទេសចរណ៍ថ្នាក់អាស៊ាន តំបន់ និងអន្តរជាតិ
- សហការរៀបចំប្រព័ន្ធគ្រប់គ្រងវិបត្តិ និងហានិភ័យនៅក្នុងវិស័យទេសចរណ៍ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអាស៊ាន និងអន្តរជាតិ
- សហការទាក់ទាញ ជំរុញវិនិយោគ និងស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីបរទេសសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍នៅកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន មានការិយាល័យចំណុះចំនួន ០៩ (**ប្រាំបួន**) ដូចខាងក្រោម៖

១-ការិយាល័យសហប្រតិបត្តិការតំបន់អាស៊ាន

២-ការិយាល័យសហប្រតិបត្តិការអង្គការជាតិ-អន្តរជាតិ និងសង្គហអភិវឌ្ឍន៍

៣-ការិយាល័យកិច្ចការនីតិកម្មអន្តរជាតិ

៤-ការិយាល័យសហប្រតិបត្តិការតំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក

៥-ការិយាល័យសហប្រតិបត្តិការតំបន់អឺរ៉ុប

៦-ការិយាល័យសហប្រតិបត្តិការតំបន់អាមេរិក អាហ្វ្រិក និងមជ្ឈឹមបូព៌ា

៧-ការិយាល័យសហប្រតិបត្តិការតំបន់អាស៊ីបូព៌ា

៨-ការិយាល័យសហប្រតិបត្តិការអនុតំបន់

៩-ការិយាល័យសហប្រតិបត្តិការឧបតោភាគីចិន។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានតួនាទី និងភារកិច្ចដូចតទៅ៖

**១-ការិយាល័យសហប្រតិបត្តិការតំបន់អាស៊ាន** មានតួនាទី និងភារកិច្ច៖

- រៀបចំផែនការសកម្មភាព និងអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយប្រទេសក្នុងតំបន់អាស៊ាន
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទេសចរណ៍អាស៊ាន
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ត្រីភាគី ពហុភាគីជាមួយប្រទេសក្នុងតំបន់អាស៊ាន
- រៀបចំកិច្ចព្រមព្រៀង អនុស្សារណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានា អនុវត្តជាមួយស្ថាប័នទេសចរណ៍អាស៊ាន
- ជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយស្ថាប័នទេសចរណ៍ក្នុងតំបន់អាស៊ាន
- រៀបចំ និងចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទេសចរណ៍អាស៊ាន អាស៊ានបូកបី ស្ថាប័នជាតិទេសចរណ៍អាស៊ាន កិច្ចប្រជុំក្រុមការងារទេសចរណ៍អាស៊ាន ព្រឹត្តិការណ៍ទេសចរណ៍ និងសន្និសីទទេសចរណ៍ថ្នាក់តំបន់អាស៊ាន
- តាមដានការអនុវត្តស្តង់ដារទេសចរណ៍អាស៊ាន
- សហការរៀបចំប្រព័ន្ធគ្រប់គ្រងវិបត្តិ និងហានិភ័យនៅក្នុងវិស័យទេសចរណ៍ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ាន។

**២-ការិយាល័យសហប្រតិបត្តិការអង្គការជាតិ-អន្តរជាតិ និងសង្គហអភិវឌ្ឍន៍** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការសកម្មភាព និងអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយអង្គការជាតិ អន្តរជាតិ ស្ថាប័នទេសចរណ៍ក្នុងវិស័យទេសចរណ៍
- រៀបចំកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាជាមួយអង្គការជាតិ អន្តរជាតិ សមាគម និងស្ថាប័នទេសចរណ៍អន្តរជាតិ
- ជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយអង្គការ សមាគម ស្ថាប័នទេសចរណ៍ និងស្ថាប័នអន្តរជាតិនានាលើវិស័យទេសចរណ៍
- កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមួយអង្គការ សមាគម និងស្ថាប័នអន្តរជាតិនានាលើវិស័យទេសចរណ៍ ដូចជាអង្គការទេសចរណ៍ពិភពលោក(UNWTO) អង្គការ UNDP, ESCAP, World Bank, ADB, PATA, ASEAN-Japan Center, ASEAN-Korean Center, ASEAN-China Center សមាគមបង្គន់អនាម័យពិភពលោក WTA និងអង្គការអភិវឌ្ឍន៍ផ្សេងៗទៀត ដើម្បីស្វែងរកសង្គហអភិវឌ្ឍន៍ និងការអភិវឌ្ឍធនធានមនុស្សលើវិស័យទេសចរណ៍។ល។
- ទំនាក់ទំនងជាមួយសហគមន៍ ស្ថាប័នទេសចរណ៍ អង្គការជាតិ អន្តរជាតិ សមាគមអន្តរជាតិ ប្រទេសផ្តល់ជំនួយ និងស្ថានទូត ដើម្បីស្នើសុំសង្គហអភិវឌ្ឍន៍ និងការអភិវឌ្ឍសមត្ថភាពជំនាញ និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យទេសចរណ៍
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ត្រីភាគី ពហុភាគីជាមួយអង្គការ សមាគម និងស្ថាប័នអន្តរជាតិនានាលើវិស័យទេសចរណ៍
- សហការទាក់ទាញ ជំរុញវិនិយោគ និងស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីបរទេស សម្រាប់អភិវឌ្ឍន៍ទេសចរណ៍នៅកម្ពុជា
- រៀបចំ និងចូលរួមកិច្ចប្រជុំ ព្រឹត្តិការណ៍ទេសចរណ៍ និងសន្និសីទទេសចរណ៍ថ្នាក់តំបន់ និងអន្តរជាតិ។

**៣-ការិយាល័យកិច្ចការនីតិកម្មអន្តរជាតិ** មានតួនាទី និងភារកិច្ចៈ

- រៀបចំចងក្រង ពិនិត្យផ្តល់យោបល់លើកិច្ចព្រមព្រៀងសហប្រតិបត្តិការ សន្ធិសញ្ញាអន្តរជាតិ កតិកាសញ្ញា អនុស្សរណៈយោគយល់គ្នា(ឧបតោភាគី ត្រីភាគី និងពហុភាគី) កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ ជំនួយស្មារតី កិច្ចសន្យា និងឯកសារគតិយុត្តនានា រវាងក្រសួងទេសចរណ៍ ជាមួយស្ថាប័នទេសចរណ៍អន្តរជាតិ ក្រុមហ៊ុន អង្គការជាតិ និងអន្តរជាតិជូនថ្នាក់ដឹកនាំក្រសួង
- រៀបចំផែនការសកម្មភាព និងអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ត្រីភាគី ពហុភាគីក្នុងតំបន់ និងអន្តរជាតិ
- គ្រប់គ្រង វិភាគ និងតាមដានសភាពការណ៍ក្នុងកិច្ចការតំបន់ និងអន្តរជាតិក្នុងវិស័យទេសចរណ៍ សេដ្ឋកិច្ចទេសចរណ៍
- តាមដាន និងជំរុញការអនុវត្តកិច្ចព្រមព្រៀង សន្ធិសញ្ញាអន្តរជាតិ កតិកាសញ្ញា អនុស្សរណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយស្ថាប័នទេសចរណ៍អន្តរជាតិ
- សហការរៀបចំប្រព័ន្ធគ្រប់គ្រងវិបត្តិ និងហានិភ័យនៅក្នុងវិស័យទេសចរណ៍ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការទេសចរណ៍តំបន់ និងអន្តរជាតិ។

**៤-ការិយាល័យសហប្រតិបត្តិការតំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការសកម្មភាព និងអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយប្រទេសក្នុងតំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការតំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ត្រីភាគី ពហុភាគី តំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក
- រៀបចំកិច្ចព្រមព្រៀង អនុស្សារណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយប្រទេសក្នុងតំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក
- ជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយស្ថាប័នទេសចរណ៍ក្នុងតំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក
- រៀបចំ និងចូលរួមកិច្ចប្រជុំ ព្រឹត្តិការណ៍ទេសចរណ៍ និងសន្និសីទទេសចរណ៍ក្នុងតំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក
- សហការរៀបចំប្រព័ន្ធគ្រប់គ្រងវិបត្តិ និងហានិភ័យនៅក្នុងវិស័យទេសចរណ៍ក្នុងក្របខណ្ឌ នៃកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីខាងត្បូង និងប៉ាស៊ីហ្វិក។

**៥-ការិយាល័យសហប្រតិបត្តិការតំបន់អឺរ៉ុប** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការសកម្មភាព និងអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយប្រទេសក្នុងតំបន់អឺរ៉ុប
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការក្នុងតំបន់អឺរ៉ុប
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ត្រីភាគី ពហុភាគីក្នុងតំបន់អឺរ៉ុប
- រៀបចំកិច្ចព្រមព្រៀង អនុស្សារណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយប្រទេសក្នុងតំបន់អឺរ៉ុប
- ជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយស្ថាប័នទេសចរណ៍ក្នុងតំបន់អឺរ៉ុប
- រៀបចំ និងចូលរួមកិច្ចប្រជុំ ព្រឹត្តិការណ៍ទេសចរណ៍ និងសន្និសីទទេសចរណ៍ក្នុងតំបន់អឺរ៉ុប
- សហការរៀបចំប្រព័ន្ធគ្រប់គ្រងវិបត្តិ និងហានិភ័យនៅក្នុងវិស័យទេសចរណ៍ក្នុងក្របខណ្ឌ នៃកិច្ចសហប្រតិបត្តិការក្នុងតំបន់អឺរ៉ុប។

**៦-ការិយាល័យសហប្រតិបត្តិការតំបន់អាមេរិក អាហ្វ្រិក និងមជ្ឈិមបូព៌ា** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការសកម្មភាព និងអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយប្រទេសក្នុងតំបន់អាមេរិក អាហ្វ្រិក និងមជ្ឈិមបូព៌ា
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការតំបន់អាមេរិក អាហ្វ្រិក និងមជ្ឈិមបូព៌ា
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ត្រីភាគី ពហុភាគី តំបន់អាមេរិក អាហ្វ្រិក និងមជ្ឈិមបូព៌ា

- រៀបចំកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយប្រទេសតំបន់អាមេរិក អាហ្វ្រិក និងមជ្ឈិមបូព៌ា
- ជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយស្ថាប័នទេសចរណ៍ក្នុងតំបន់អាមេរិក អាហ្វ្រិក និងមជ្ឈិមបូព៌ា
- រៀបចំ និងចូលរួមកិច្ចប្រជុំ ព្រឹត្តិការណ៍ទេសចរណ៍ និងសន្និសីទទេសចរណ៍ក្នុងតំបន់អាមេរិក អាហ្វ្រិក និងមជ្ឈិមបូព៌ា
- សហការរៀបចំប្រព័ន្ធគ្រប់គ្រងវិបត្តិ និងហានិភ័យនៅក្នុងវិស័យទេសចរណ៍ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការក្នុងតំបន់អាមេរិក អាហ្វ្រិក និងមជ្ឈិមបូព៌ា

**៧-ការិយាល័យសហប្រតិបត្តិការតំបន់អាស៊ីបូព៌ា** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការសកម្មភាព និងអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយប្រទេសក្នុងតំបន់អាស៊ីបូព៌ា
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការតំបន់អាស៊ីបូព៌ា
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ក្នុងក្របខណ្ឌទ្វេភាគី ត្រីភាគី ពហុភាគីតំបន់អាស៊ីបូព៌ា
- រៀបចំកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយប្រទេសតំបន់អាស៊ីបូព៌ា
- ជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយស្ថាប័នទេសចរណ៍ក្នុងតំបន់អាស៊ីបូព៌ា
- រៀបចំ និងចូលរួមកិច្ចប្រជុំ ព្រឹត្តិការណ៍ទេសចរណ៍ និងសន្និសីទទេសចរណ៍ក្នុងតំបន់អាស៊ីបូព៌ា
- សហការរៀបចំប្រព័ន្ធគ្រប់គ្រងវិបត្តិ និងហានិភ័យនៅក្នុងវិស័យទេសចរណ៍ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីបូព៌ា

**៨-ការិយាល័យសហប្រតបត្តិការអនុតំបន់** មានតួនាទី និងភារកិច្ចៈ

- ធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការទេសចរណ៍ជាមួយបណ្តាប្រទេសនៅក្នុង តំបន់អនុតំបន់ CLV, CLMV, CLMTV, ACMECS, ACD, Mekong-Langcang, Mekong-Gonga, Mekong-Japan, Mekong-Korea, CICA...។ល។
- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍នៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការក្នុងអនុតំបន់ CLV, CLMV, CLMTV, ACMECS, ACD, Mekong-Langcang, Mekong-Gonga, Mekong-Japan, Mekong-Korea, CICA...។ល។
- រៀបចំ និងចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទេសចរណ៍ ស្ថានប័នជាតិទេសចរណ៍ កិច្ចប្រជុំក្រុមការងារទេសចរណ៍ សិក្ខាសាលា សន្និសីទ វគ្គបណ្តុះបណ្តាលផ្នែកទេសចរណ៍ និងព្រឹត្តិការណ៍ផ្សេងៗទៀតក្នុងអនុតំបន់ CLV, CLMV, CLMTV, ACMECS, ACD, Mekong-Langcang, Mekong-Gonga, Mekong-Japan, Mekong-Korea, CICA... ។ល។
- រៀបចំចងក្រងកិច្ចព្រមព្រៀងសហប្រតិបត្តិការ អនុស្សរណៈយោគយល់គ្នា (ឧបតោភាគី ត្រីភាគី និងពហុភាគី) កំណត់ហេតុ និងជំនួយស្មារតី និងកិច្ចសន្យារវាងក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាបន័ទេសចរណ៍បណ្តាប្រទេសក្នុងអនុតំបន់ CLV, CLMV, CLMTV, ACMECS, ACD, Mekong-Langcang, Mekong-Gonga, Mekong-Japan, Mekong-Korea, CICA...។ល។

- ជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តជាមួយស្ថាប័នទេសចរណ៍ក្នុងអនុតំបន់ CLV, CLMV, CLMTV, ACMECS, ACD, Mekong-Langcang, Mekong-Gonga, Mekong-Japan, Mekong-Korea, CICA...។ល។
- ស្រាវជ្រាវរកឯកសារគតិយុត្តិនានារបស់ស្ថាប័នទេសចរណ៍ក្នុងអនុតំបន់ ដើម្បីវិភាគ និងធ្វើជាបទពិសោធន៍ក្នុងការចងក្រង និងរៀបចំធ្វើឯកសារគតិយុត្តិនានា។

**៩-ការិយាល័យសហប្រតិបត្តិការឧបតោភាគីចិន មានតួនាទី និងភារកិច្ចៈ**

- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ផែនការសកម្មភាព និងអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទេសចរណ៍រវាងកម្ពុជា-ចិន
- រៀបចំកិច្ចព្រមព្រៀង អនុស្សារណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តរវាងកម្ពុជា-ចិន
- ជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សារណៈយោគយល់គ្នា ជំនួយស្មារតី កិច្ចសន្យា កំណត់ហេតុ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងឯកសារគតិយុត្តនានាអនុវត្តរវាងកម្ពុជា-ចិន
- រៀបចំ និងចូលរួមកិច្ចប្រជុំ ព្រឹត្តិការណ៍ទេសចរណ៍ និងសន្និសីទទេសចរណ៍ក្នុងក្របខណ្ឌកម្ពុជា-ចិន
- សិក្សារៀបចំគម្រោងអាទិភាពពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ គម្រោងវិនិយោគទាំងសាធារណៈ និងឯកជនលើវិស័យទេសចរណ៍ ដើម្បីទាក់ទាញ និងគៀងគរប្រភពជំនួយហិរញ្ញវត្ថុពីប្រទេសចិន
- ជំរុញអនុវត្តស្មារតីគំនិតផ្តួចផ្តើម "**ខ្សែក្រវ៉ាត់មួយ វិថីមួយ**-One Belt One Road" ដែលជាក្របខណ្ឌគោលនយោបាយឈ្នះឈ្នះរបស់រដ្ឋាភិបាលចិន ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងទេសចរណ៍ពហុជាតិនៅប្រទេសតាមផ្លូវសូត្រ-Silk Road
- សម្របសម្រួលការផ្លាស់ប្តូរព័ត៌មានទេសចរណ៍ សម្រួលការធ្វើដំណើរ និងកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្ស ជំនាញវិជ្ជាជីវៈទេសចរណ៍ បដិសណ្ឋារកិច្ចសម្រាប់ទីផ្សារទេសចរណ៍ចិន និងការអភិវឌ្ឍសមត្ថភាពជំនាញទេសចរណ៍សម្រាប់មន្ត្រីទេសចរណ៍ និងផ្នែកឯកជន
- សហការជាមួយភាគីពាក់ព័ន្ធអនុវត្តផែនការសកម្មភាព សៀវភៅស ស្តីពីទីផ្សារទេសចរណ៍ចិន និងការត្រៀមលក្ខណៈសម្បត្តិទទួលទេសចរចិន (China Ready) សម្រាប់ទេសចរណ៍កម្ពុជា សំដៅទាក់ទាញទេសចរចិនឱ្យបានយ៉ាងតិច ២លាននាក់ ក្នុងមួយឆ្នាំៗចាប់ពីឆ្នាំ២០២០
- សហការរៀបចំប្រព័ន្ធគ្រប់គ្រងវិបត្តិ និងហានិភ័យនៅក្នុងវិស័យទេសចរណ៍រវាងកម្ពុជា-ចិន។

**ប្រការ ៦.-**

ការិយាល័យនីមួយៗ ចំណុះឲ្យនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន មានតួនាទី និងភារកិច្ចៈ

- រៀបចំចងក្រង ថែរក្សាលិខិតបទដ្ឋានគតិយុត្ត ឯកសារសិក្សាស្រាវជ្រាវ ដែលមានការពាក់ព័ន្ធតាមផ្នែកនីមួយៗ
- លើកគម្រោង និងអនុវត្តទិសដៅស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍របស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងទេសចរណ៍
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ និងរបាយការណ៍ពីភាពមិនប្រក្រតីកើតមានឡើង
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍ រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ